## ★ ការជជែកយល់ស្រប នូវសំណើ 50 ★

បោះឆ្នោត បាទ/ចាស ទៅលើសំណើ 50—អនុញ្ញាតឲ្យអង្គនីតិបញ្ញត្តិ ដើម្បីព្យួរសមាជិក ដោយគ្មានប្រាក់ខែ

សំណើ 50 នឹងកែប្រែរដ្ឋធម្មនុញ្ញរដ្ឋ ដើម្បីផ្តល់ឲ្យអង្គនីតិបញ្ញត្តិរដ្ឋកាលីហ្វ័រនីញ៉ា នូវអាជ្ញាច្បាស់លាស់ ដើម្បីព្យួរសមាជិកព្រឹទ្ធសភា ឬសមាជិកសភា ដោយគ្មានប្រាក់ខែ។

វិធានការនេះគឺជាសមញ្ញ និងជាមធ្យោបាយត្រង់ភ្លឹង សំរាប់អ្នកតែងច្បាប់ ដើម្បីបង្ខំសហការីរបស់ខ្លួនឲ្យចេះទទួលខុសត្រូវ សំរាប់ការល្មើសសេចក្តីទុកចិត្តរបស់សាធារណជន។

នៅបច្ចុប្បន្ននេះ រដ្ឋធម្មនុញ្ញរដ្ឋកាលីហ្វ័រនីញ៉ា មិនមានភាពច្បាស់លាស់ ថាអង្គនីតិបញ្ញត្តិអាចព្យួរសមាជិកដោយគ្មានប្រាក់ខែឡើយ។ រឿងរ៉ាវនេះបានលេចធ្លោនៅក្នុងឆ្នាំ 2014 នៅពេលព្រឹទ្ធសភារដ្ឋបីនាក់—ទាំងអស់បានជាប់ចោទបទឧក្រឹដ្ឋ—ដែលត្រូវបានព្យួរដោយដំណោះស្រាយនៃព្រឹទ្ធសភា។

ប៉ុន្តែសមាជិកទាំងនោះនៅតែបានបន្តទទួលប្រាក់ខែរបស់គេ—លើសពី $95,000 ក្នុងមួយឆ្នាំ—ពីព្រោះវាមិនច្បាស់លាស់ ថាព្រឹទ្ធិសភាមានអាជ្ញាធរ ដើម្បីព្យួរប្រាក់ខែរបស់គេបានដែរឬអត់។

ឧប្បត្តិហេតុនេះបានធ្វើឲ្យអ្នកតែងច្បាប់អន្ទះអន្ទែង ដែលចង់បង្ខំសមាជិករបស់ខ្លួនឲ្យចេះទទួលខុសត្រូវ និងបានធ្វើឲ្យសាធារណជនខឹងសំបារ ដែលបានឃើញវាថាជាគំរូមួយទៀត នៃរបៀបដែលអ្នកតែងច្បាប់បានបិទបាំងផលវិបាកនៃការប្រព្រឹត្តិរបស់ខ្លួនគេ និងលេងតាមច្បាប់មួយ ផ្សេងពីអ្នកឯទៀតៗ។

សារព័ត៌មាន *San Francisco Chronicle* បានសរសេរថា "វាគឺជាស្ថានការណ៍គួរ ឲ្យខ្មាញ់ដែលអនុញ្ញាតឲ្យបើកប្រាក់ខែពេញ ដោយមិនធ្វើការអ្វីសោះ" ដោយទទូច ឲ្យអ្នកតែងច្បាប់កែប្រែកលល្បិចនេះ។

អង្គនីតិបញ្ញត្តិបានយករឿងនេះដោយខ្លួនគេដើម្បីធ្វើការនោះ។ អ្នកតែងច្បាប់បាននិពន្ធ និងបានអនុម័ត—ដោយមតិលើសលប់ និងក៏មានការគាំទ្រដ៏ខ្លាំងពីបក្សទាំងពីរ—វិសោធនកម្មរដ្ឋធម្មនុញ្ញនេះ ហើយវាក៏បានដាក់នៅមុខអ្នកបោះឆ្នោត សំរាប់ការយល់ព្រមពីគេ។

វិសោធនកម្មរដ្ឋធម្មនុញ្ញនឹងតម្រូវឲ្យសភា និងព្រឹទ្ធសភា អនុម័តនូវដំណោះស្រាយដែលប្រកាសពីមូលហេតុដែលសមាជិកត្រូវបានព្យួរ។ និងក៏ត្រូវការពារ ប្រឆាំងនឹងការប្រើប្រាស់នយោបាយខុសឆ្គង ហើយដំណោះស្រាយនឹងតម្រូវឲ្យមានកំរិតខ្ពស់ជាង ដោយមានសំឡេងឆ្នោត ពីរ-ភាគបី សំរាប់ការយល់ព្រម។

មហាសន្និបាទជាតិនៃអង្គនីតិបញ្ញត្តិរដ្ឋ (National Conference of State Legislatures) ជឿថាអំណាចដើម្បីដាក់ពិន័យ និងបណ្តេញ សមាជិកចេញ គឺជាប់ជាមួយតួអង្គនីតិបញ្ញត្តិ។ ជាយូរយាមកហើយ អំណាចនេះគឺជាមូលដ្ឋាននៃលទ្ធិប្រជាធិបតេយ្យអាមេរិកាំង។ វាគឺជាការអនុវត្តន៍ទូទៅ នៅក្នុងរដ្ឋភាគច្រើន។

អង្គនីតិបញ្ញត្តិរដ្ឋកាលីហ្វ័រនីញ៉ា មានអំណាចបណ្តេញសមាជិកចេញ ហើយវាគួរតែមានអាជ្ញាធរដើម្បីព្យួរគេ ដោយគ្មានប្រាប់ខែ ប្រសិនបើមានកាលៈទេសៈបែបនេះកើតឡើង។

ពលរដ្ឋកាលីហ្វ័រនីញ៉ា ចង់បាន និងចង់មានរដ្ឋាភិបាលមួយដែលជាទីទំនុកចិត្តរបស់គេ។ អ្នកបោះឆ្នោតបានអនុម័តការកែទំរង់នយោបាយជាច្រើន នៅក្នុងទសវត្សរ៍កន្លងមក ដើម្បីកែលំអការគ្រប់គ្រងក្នុងរដ្ឋកាលីហ្វ័រនីញ៉ា ប៉ុន្តែមានជាច្រើនទៀតដែលត្រូវធ្វើ ដើម្បីស្តាបនាឡើងវិញនូវការទុកចិត្តពីសាធារណជន។

សំណើ 50 គឺជាជំហានសុភវិនិច្ឆ័យមួយ ដែលនឹងផ្តល់អាជ្ញាធរឲ្យអ្នកតែងច្បាប់ ដើម្បីល្បាតខ្លួនគេ ដែលជាជំហានត្រឹមត្រូវបន្ទាប់ទៀត ដើម្បីបង្ខំ ឲ្យអ្នកតែងច្បាប់ចេះទទួលខុសត្រូវ សំរាប់ការបំរើផលប្រយោជន៍របស់សាធារណជន។

ហេតុនោះហើយ បានជាពលរដ្ឋកាលីហ្វ័រនីញ៉ាដែលមានចិត្តយុត្តិធម៌ គាំទ្រសំណើ 50។

**HELEN HUTCHISON,** ប្រធាន
League of Women Voters of California

**JAMES P. MAYER,** ប្រធាន/នាយកប្រតិបត្តិ
California Forward

## ★ ការច្រានចោល ចំពោះការជជែកយល់ស្រប នូវសំណើ 50 ★

តើហេតុអ្វីបានជាអង្គនីតិបញ្ញត្តិ បោះឆ្នោតដើម្បីបន្ថែមសំណើ 50 ទៅលើសន្លឹកឆ្នោត?

ពីព្រោះតែសំណើ 50 ផ្តល់ជំរើសឲ្យអ្នកដឹកនាំអង្គនីតិបញ្ញត្តិ មិនបណ្តេញគូកនសមាជិកសភារបស់គេ និងព្រឹទ្ធសភាដែលបានជាប់ចោទ ឬបានជាប់ទោសបទឧក្រិដ្ឋ។

សំណើ 50 គឺមិនចាំបាច់ទេ ពីព្រោះរដ្ឋធម្មនុញ្ញរដ្ឋកាលីហ្វ័រនីញ៉ា អនុញ្ញាតឲ្យសមាជិកសភា និងព្រឹទ្ធសភាដែលបានជាប់ចោទ ឬបានជាប់ទោសបទឧក្រិដ្ឋត្រូវបានដកចេញពីការិយាល័យ ដោយបណ្តេញគេចេញ ជាស្រេចហើយ។

ផ្ទុយទៅវិញ សំណើ 50 អនុញ្ញាតឲ្យអស់អ្នកទាំងនោះនៅក្នុងអង្គនីតិបញ្ញត្តិ ដែលបានជាប់ចោទ ឬបានជាប់ទោសបទឧក្រិដ្ឋ ត្រូវបានព្យួរដោយមាន ឬគ្មានប្រាក់ខែ ហើយវាលួចសមាជិកនៃមណ្ឌលបោះឆ្នោត នូវការតំណាងរបស់គេ។ សំរាប់ពលរដ្ឋកាលីហ្វ័រនីញ៉ាជាច្រើននាក់វិញ អ្នកនយោបាយបានអនុញ្ញាតឲ្យបំរើនៅក្នុងការិយាល័យរបស់គេ ជាយូរណាស់រួចមកហើយ។ ការអនុញ្ញាតឲ្យគេបន្តនៅក្នុងការិយាល័យ បន្ទាប់ពីបានប្រព្រឹត្តិឧក្រិដ្ឋកម្ម នៅក្រោមសំណើ 50 គឺខុសស្រឡះ!

បើអ្នកជឿថាសមាជិកសភា និងព្រឹទ្ធសភា មិនគួរជិះជាន់ច្បាប់ទេ សូមបោះឆ្នោត ទេ និងផ្ញើសារយ៉ាងច្បាស់លាស់ថាៈ លែងមានឯកសិទ្ធិពិសេសទៀតហើយ សំរាប់សមាជិកសភា និងព្រឹទ្ធសភា ដែលបានជាប់ចោទ ឬបានជាប់ទោសបទឧក្រិដ្ឋ។

ពលរដ្ឋកាលីហ្វ័រនីញ៉ា គប្បីបានសេចក្តីស្មោះត្រង់ពីអ្នកតំណាងដែលបំរើគេ—មិនមែននីតិបុគ្គលដែលបានជាប់ចោទ ឬបានជាប់ទោស ដែលត្រូវបានព្យួរពីភារៈកិច្ចរបស់គេ តែនៅក្នុងការិយាល័យដដែល ដែលសំណើ 50 អនុញ្ញាតឡើយ។

បោះឆ្នោត ទេ ទៅលើសំណើ 50—ត្រូវបញ្ឈប់ អំពើពុករលួយ!

**JON FLEISCHMAN,** ប្រធាន
California Term Limits

**RUTH WEISS,** អ្នកសំរបសំរួលខោនធី San Diego
California Election Integrity Project



*ការជជែកដែលបានផ្តិតនៅលើទំព័រនេះ គឺជាមតិរបស់អ្នកនិពន្ធ និងមិនទាន់បានពិនិត្យមើលភាពត្រឹមត្រូវ ដោយមន្ត្រីភ្នាក់ងារណាមួយនៅឡើយទេ។*

## ★ ការជជែកប្រឆាំងនឹង សំណើ 50 ★

សំណើ 50 គឺជាការបោកបញ្ឆោត បាននាំមកឲ្យអ្នក ដោយអស់អ្នកដែលនឹងធ្វេចភ្នែក ចំពោះវប្បធម៌នៃអំពើពុករលួយ នៅក្នុងវិមានរដ្ឋសភារបស់យើង! អ្នកបោះឆ្នោតគួរតែជំទាស់វិធានការនេះ ពីព្រោះតែ:

វាធ្វើឲ្យមានវប្បធម៌ពុករលួយ ជារហូតនៅក្នុងវិមានរដ្ឋសភា

វាបង្កើតការបង់ពន្ធ ដោយគ្មានការតំណាង

អ្នកនៅក្នុងវិមានរដ្ឋសភា អាចប្រើវាដើម្បីបង្ក្រាបការជំទាស់នយោបាយ

ធ្វើឲ្យមានវប្បធម៌ពុករលួយ ជារហូតនៅក្នុងវិមានរដ្ឋសភា

ក្នុងឆ្នាំ 2014 នៅពេលវិធានការនេះត្រូវបានដាក់លើសន្លឹកឆ្នោត ស្ទើរតែម្នាក់ក្នុងបណ្តាជប់អ្នកនៃព្រឹទ្ធសភារដ្ឋកាលីហ្វ័រនីញ៉ា ត្រូវបានជាប់ចោទ ឬនៅក្រោមការជាប់ទោសបទឧក្រិដ្ឋជាច្រើន រួមទាំង ការក្លែងបន្លំ ការស៊ីសំណូក និងសូម្បីតែការជួញអាវុធ។ ក្នុងខណៈរឿងនេះកំពុងតែមាននៅឡើយ អ្នកនិពន្ធសំណើ 50 ជាបន្ទាប់មកប្រធាននៃព្រឹទ្ធសភានៅពេលនោះ នៃរដ្ឋកំពុងក្តៅបក្តាប់ បានប្រកែកដើម្បីពិចារណា ពីការបណ្តេញមនុស្សចោលម្បៀតទាំងនេះ ចេញពីការិយាល័យរបស់គេ ដែលជាទំនុកចិត្តនៃសាធារណជន—សូម្បីតែបន្ទាប់ពីម្នាក់ក្នុងពួកគេ ត្រូវបានកាត់ ឲ្យជាប់ទោស ដោយគណៈវិនិច្ឆ័យក្តី!

ដើមរឿងសំខាន់ នៅក្នុងសារព័ត៌មាន រួមមាននូវ:

"បំណងបណ្តេញព្រឹទ្ធសភារដ្ឋ ត្រូវបានរារាំង"—*Capital Public Radio*, 2/27/14

"ទោសវិនិច្ឆ័យ Wright ត្រូវបានពន្យារពេល; ព្រឹទ្ធសភាប្រកែកដើម្បីបណ្តេញមនុស្សនៃបក្សប្រជាធិបតេយ្យដែលបានជាប់ទោស"—*Breitbart News Network*, 7/8/14

សំណើ 50 គឺបានតាក់តែងឡើងដើម្បីធ្វើឲ្យអ្នកដូចជាមានវណ្ណៈនយោបាយនៅ Sacramento ដែលតាមពិតចង់ធ្វើឲ្យមានគោលជំហរពិបាក ដើម្បីគាស់ឫសគល់នៃអំពើពុករលួយ។ អ្វីៗដែលគេពិតជាធ្វើ គឺកំពុងតែលាក់បាំងការណ៍ពិតមិនឲ្យអ្នកដឹង ថាគេនឹងមិនធ្វើការសំរេចឲ្យចាស់ដៃ ដើម្បីបណ្តេញគូកនរបស់គេ—ដែលជាប់ទោសបទឧក្រិដ្ឋឡើយ។

ការបង់ពន្ធ ដោយគ្មានការតំណាង

សំណើ 50 ក៏បដិសេធពលរដ្ឋកាលីហ្វ័រនីញ៉ារាប់លាននាក់ នូវសិទ្ធិជាមូលដ្ឋានរបស់គេដែរ។ វាបង្ខំឲ្យបង់ពន្ធ ដោយគ្មានការតំណាង។ នៅពេលនីតិបុគ្គលត្រូវបាន "ព្យួរ" ជាជាងបានបណ្តេញចេញ នោះមានន័យថាពលរដ្ឋនៅក្នុងមណ្ឌលនោះគ្មានអ្នកណាម្នាក់ តំណាងឲ្យផលប្រយោជន៍របស់គេ នៅក្នុងអង្គនីតិបញ្ញត្តិរដ្ឋឡើយ។ វាមានន័យថាគ្មានការបោះឆ្នោតអាចកើតឡើង ដើម្បីជំនួសតួភាពយន្តអាក្រក់នោះឡើយ ពីព្រោះពួកគាត់នៅតែ "កាន់កាប់" ការិយាល័យជាដដែល។

អ្នកនៅក្នុងវិមានរដ្ឋសភា អាចប្រើសំណើ 50 ដើម្បីបង្ក្រាបការជំទាស់ នយោបាយ

ប្រហែលជាផ្នែកដ៏រំខានបំផុតនៃវិធានការនេះ គឺថាវាដាក់ចូលទៅក្នុងរដ្ឋធម្មនុញ្ញរដ្ឋជាអចិន្ត្រៃយ៍ ដែលមានន័យថាមតិភាគច្រើនអាចបង្ក្រាបមតិភាគតិច នៅក្នុងអង្គនីតិបញ្ញត្តិ។ វាមិនពិបាកឃើញនៅទីណាឡើយ បើអ្នកជាសមាជិកនៃព្រឹទ្ធសភាឬសភា ដែលមានវោហារទៅលើរឿងរ៉ាវមួយដែលមិនប្រជាប្រិយ ជាមួយសហការីរបស់អ្នក នោះអ្នកអាចនឹងប្រឈមមុខចំពោះភាពពិតថាគេអាចបោះឆ្នោតដើម្បីព្យួរ—ដើម្បីដកសំឡេងរបស់អ្នកចេញ និងសំឡេងឆ្នោតរបស់អ្នកនៅក្នុងអង្គនីតិបញ្ញត្តិ!

បោះឆ្នោត ទេ ទៅលើសំណើ 50!

មើល: *Stopprop50.com*

**JOEL ANDERSON,** ព្រឹទ្ធសភា
មណ្ឌលទី 38

**BRIAN JONES,** សមាជិកសភា
មណ្ឌលទី 71

## ★ ការច្រានចោល ចំពោះការជជែកប្រឆាំង នូវសំណើ 50 ★

វិធានការនេះនឹងផ្តល់ឲ្យអ្នកតែងច្បាប់នូវអាជ្ញាធរដែលត្រូវការ ដើម្បីដាក់ពិន័យគូកនសមាជិកសភា និងព្រឹទ្ធសភា—ដោយធ្វើការពិចារណាហេតុភេទនៃការចោទប្រកាន់ និងកាលៈទេសៈផ្សេងៗទៀត។

នៅក្នុងករណីធ្ងន់ធ្ងរ សភា និងព្រឹទ្ធិសភា មានអាជ្ញាធរដើម្បីបណ្តេញសមាជិករួចហើយ។ ប៉ុន្តែការបណ្តេញចេញគឺមិនមែនតែងតែជាការឆ្លើយតបឡើយ។ សូម្បីតែនៅពេលអ្នកតែងច្បាប់ត្រូវបានជាប់ចោទបទឧក្រិដ្ឋ ដោយបានសន្មតថាគ្មានទោសគង់តែវាអាចនឹងមិនត្រឹមត្រូវដើម្បីបណ្តេញបុគ្គលនោះបានឡើយ រហូតទាល់តែបានដឹងការណ៍ពិតទាំងអស់ ហើយបានដោះស្រាយរឿងក្តី។

នៅក្នុងស្ថានភាពបែបនោះជាច្រើន អ្នកតែងច្បាប់ត្រូវការអាជ្ញាធរដើម្បីឆ្លើយតបដោយសមហេតុសមផល និងក្នុងលក្ខណៈសមរម្យ—ដើម្បីធ្វើអ្វីៗ ឲ្យខ្លី ពីការបណ្តេញសមាជិកចេញពីអង្គនីតិបញ្ញត្តិ និងអ្វីៗលើសពីការអនុញ្ញាតសមាជិកនោះឲ្យអង្គុយនៅផ្ទះនិងប្រមូលប្រាក់ខែពីអ្នកបង់ពន្ធ។

សំណើ 50 ផ្តល់ឲ្យសភា ឬព្រឹទ្ធសភា អាចព្យួរសមាជិក—និងព្យួរប្រាក់ខែរបស់សមាជិក។

សំណើនេះដាក់រនាំងខ្ពស់ ដើម្បីការពារអ្នកតែងច្បាប់ ពីការដាក់ទណ្ឌកម្មគ្នាទៅវិញទៅមកដោយអយុត្តិធម៌។ វាតម្រូវឲ្យវិមានសភាប្រកាសជាសាធារណៈ អំពីមូលហេតុសំរាប់ការប្រព្រឹត្តិរបស់ខ្លួន និងដំណោះស្រាយ ត្រូវតែបានយល់ព្រមដោយសំឡេងឆ្នោតពីរ-ភាគបី—មិនដែលងាយស្រួលឡើយ និងសឹងតែត្រូវការគាំទ្រពីបក្សទាំងពីរជានិច្ច។

វិធានការនេះមិនឃាត់ឃាំងអង្គនីតិបញ្ញត្តិ ឬអ្នកតែងច្បាប់ ពីអានុភាពដែលពុករលួយ និងត្រូវបានធ្វើថែមទៀត ដើម្បីជំរុញឲ្យមានឥរិយាបថ ប្រកបដោយសីលធម៌ បង្កើនតម្លាភាព សើបអង្កេតជំរុញ និងការប្រតិបត្តិច្បាប់។

សំណើ 50 ផ្តល់ឲ្យអ្នកតែងច្បាប់នូវមធ្យោបាយមួយទៀត ដើម្បីឆ្លើយតបការបំពានសីលធម៌ ដោយធ្វើវាឲ្យច្បាស់លាស់ ថានៅពេលមាន កាលៈទេសៈដូច្នោះកើតឡើង អ្នកតែងច្បាប់អាចត្រូវបានព្យួរដោយគ្មានប្រាក់ខែ។

**JAMES P. MAYER,** ប្រធាន/នាយកប្រតិបត្តិ
California Forward

**HELEN HUTCHISON,** ប្រធាន
League of Women Voters of California

*ការជជែកដែលបានផ្តិតនៅលើទំព័រនេះ គឺជាមតិរបស់អ្នកនិពន្ធ និងមិនទាន់បានពិនិត្យមើលភាពត្រឹមត្រូវ ដោយមន្ត្រីភ្នាក់ងារណាមួយនៅឡើយទេ។*